ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.ធ.៧ ០១៩...០២៣..ប្រ.ភ.ស.ព័ត៌មាន

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ខេត្តសៀមរាប ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន ស្តីពី
# សិក្ខាសាលា NBC-ADBI-OECD ថ្នាក់តំបន់ ស្តីពី
# "តួនាទីនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន ក្នុងការគាំទ្របរិយាបន្នហិរញ្ញវត្ថុ"

នាថ្ងៃព្រហស្បតិ៍ ១០រោច និងសុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២១-២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI) និងអង្គការដើម្បីអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) បានរៀបចំសិក្ខាសាលា NBC-ADBI-OECD ថ្នាក់តំបន់ ស្តីពី "តួនាទីនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជនក្នុងការគាំទ្របរិយាបន្នហិរញ្ញវត្ថុ" នៅសណ្ឋាគារបុរីអង្គរ ខេត្តសៀមរាប ក្រោមអធិបតីភាពរបស់ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីសិក្ខាកាមជាតិមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍នានា និងសិក្ខាកាមនិងវាគ្មិនអន្តរជាតិសរុបប្រមាណ ១១០នាក់។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ចែករំលែកចំណេះដឹង បញ្ហាប្រឈម និងឧត្តមានុវត្តភាពនៃការអនុវត្ត ដើម្បីជំរុញបរិយាបន្នហិរញ្ញវត្ថុ តាមរយៈការរៀបចំនិងអនុវត្តគោលនយោបាយចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជនប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ សិក្ខាសាលាក៏បានផ្តល់ជាវេទិកាសម្រាប់ការពិភាក្សាអំពី យុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុ ដើម្បីជំរុញប្រតិបត្តិការសន្សំនិងឥណទាននៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ពង្រីកប្រតិបត្តិការទូទាត់ និងលើកកម្ពស់សិទ្ធិអតិថិជន ដើម្បីធានាតម្លាភាពនៅក្នុងវិស័យហិរញ្ញវត្ថុ ដែលនឹងជួយជំរុញដល់ការសម្រេចបានកំណើនប្រកបដោយចីរភាព។

សិក្ខាសាលាក៏បានពិភាក្សាអំពីវិធីសាស្ត្រនៃការអនុវត្តក្នុងការលើកកម្ពស់និងផ្សព្វផ្សាយអំពីការអប់រំផ្នែកហិរញ្ញវត្ថុឲ្យបានទូលំទូលាយដល់ក្រុមគោលដៅមួយចំនួន ដូចជា សិស្សនិស្សិត សហគ្រាសធុនតូចបំផុតនិងមធ្យម និងស្ត្រី ក្នុងបរិការណ៍ដែលបច្ចេកវិទ្យាហិរញ្ញវត្ថុកំពុងលូតលាស់។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៩២៦ ១១៧

ការអប់រំផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន បានដើរតួនាទីចម្បងក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ការអប់រំផ្នែកហិរញ្ញវត្ថុ អាចជួយជំរុញកម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដែលជាលទ្ធផលនឹងអាចជួយគាំទ្រដល់ស្ថិរភាពហិរញ្ញវត្ថុផងដែរ។ ទិន្នន័យពាក់ព័ន្ធនឹងកម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុមានសារៈសំខាន់សម្រាប់ការរៀបចំនិងការអនុវត្តគោលនយោបាយ និងការអភិវឌ្ឍយុទ្ធសាស្ត្រអប់រំផ្នែកហិរញ្ញវត្ថុ ដែលជួយជំរុញដល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងបរិយាបន្នហិរញ្ញវត្ថុ។ ដើម្បីបង្កើតឲ្យមានបរិយាបន្នហិរញ្ញវត្ថុដ៏រឹងមាំមួយ ការលើកកម្ពស់សិទ្ធិនិងកិច្ចការពារអតិថិជនពិតជាមានសារៈសំខាន់ណាស់ ជាពិសេសនៅពេលដែលគោលនយោបាយការពារអតិថិជនត្រូវបានរៀបចំឡើងសម្រាប់ភាគីពាក់ព័ន្ធ នៅពេលដែលបច្ចេកវិទ្យាហិរញ្ញវត្ថុមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

ចំពោះផែនការទៅអនាគត ផ្អែកលើអនុស្សរណៈយោគយល់គ្នាជាផ្លូវការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងកិច្ចការនារី អាទិភាពចម្បងរបស់ភាគីទាំងបីគឺផ្តោតទៅលើការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សិស្សានុសិស្ស និងក្រុមស្ត្រីគោលដៅ។ កិច្ចសហប្រតិបត្តិការទាំងនេះនឹងត្រូវបន្ត ដើម្បីធានាសម្រេចឲ្យបាននូវគោលដៅដែលបានកំណត់ក្នុង យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។

ជាលទ្ធផល សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយជោគជ័យ ដោយមានការចាប់អារម្មណ៍ និងពិភាក្សាយ៉ាងផុសផុលលើប្រធានបទខាងលើនេះ។ សិក្ខាសាលានេះបានផ្តល់ឱកាសដល់សិក្ខាកាមស្វែងយល់កាន់តែស៊ីជម្រៅអំពីសារៈសំខាន់នៃចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជនក្នុងការគាំទ្របរិយាបន្នហិរញ្ញវត្ថុ តាមរយៈការចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងវិធីសាស្ត្រនៃការអនុវត្តពីសំណាក់ភាគីពាក់ព័ន្ធ ដើម្បីជំរុញឲ្យបរិយាបន្នហិរញ្ញវត្ថុក្នុងតំបន់អាចសម្រេចបានយ៉ាងឆាប់រហ័ស។

**សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរសព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh